# អំពីស្ថានភាពមន្ត្រី

| | |
|---|---|
| ១៩៩៣-១៩៩៨ | អណត្តិទី១ បុគ្គលិក ២៣៧នាក់ |
| ខែមិនា ១៩៩៩-២០០៣ | អណត្តិទី២ **សម្តេចក្រុមព្រះ** ធ្វើប្រធានរដ្ឋសភា |
| | បុគ្គលិកពេញសិទ្ធ ៣៨៩នាក់ |
| | បុគ្គលិកអណ្តែត ១២២នាក់ |
| | បុគ្គលិកកិច្ចសន្យា ៣២នាក់ |
| ២០០៣-២០០៦ | អណត្តិទី៣ **សម្តេចក្រុមព្រះ**លាលែង ខែមីនា ឆ្នាំ២០០៦ |
| | បុគ្គលិកឡើងដល់ជាង ៥០០នាក់ |
| ដោយសារ-ទី១៖ | គណបក្សហ៊្វុនស៊ិនប៉ិច បានបញ្ចូលមន្ត្រីប្រមាណជិត ១០០នាក់ |
| -ទី២៖ | គណបក្សប្រជាជនកម្ពុជា ដោយ**ឯកឧត្តម ខួន ញ៉ិល** |
| | បានស្នើសុំបញ្ចូលបុគ្គលិក ១៦៨នាក់ |
| | និង**ឯកឧត្តម ចាន់ វ៉ែន** ស្នើសុំមួយចំនួន |
| ២០០៦-២០០៨ | **សម្តេច ហេង សំរិន** ឡើងធ្វើប្រធានរដ្ឋសភាបន្ត |
| | បុគ្គលិកឡើងដល់ចំនួន ១,១៣៥នាក់ |
| ២០០៨-២០១៣ | អណត្តិទី៤ ១,៣១៨នាក់ |
| ២០១៣-តុលា ២០១៤ | អណត្តិទី៥ **សម្តច ហេង សំរិន** តួលេខឡើងដល់ ១,៣៤០នាក់ |
| | បច្ចុប្បន្ន ១,៣៥១នាក់ |

ការដែលថាបុគ្គលិកមានតាំងពីជំនាន់**សម្តេចក្រុមព្រះ** និងតាមគោលការណ៍បង្រួបបង្រួមជាតិនោះ ពុំពិតទេ។ ពីព្រោះសម្តេចក្រុមព្រះ លាលែងពីប្រធានរដ្ឋសភា នៅខែកុម្ភៈ ឆ្នាំ២០០៦។ តាមតួលេខបង្ហាញតាំងពី**សម្តេច ហេង សំរិន** ឡើងធ្វើប្រធានរដ្ឋសភា មានបុគ្គិលឡើងពាក់ កណ្តាលនៃចំនួនពីសម្តេចក្រុមព្រះ។

# **អំពីការចាត់តាំង**

នៅ**នីតិកាលទី១** ១៩៩៣-១៩៩៨ អគ្គលេខាធិការដ្ឋានរដ្ឋសភា មាននាយកដ្ឋាន៤ គឺ នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋាននីតិវិធី នាយកដ្ឋានស្រាវជ្រាវ និងមាន ការិយាល័យចំនួន២ គឺ ការិយាល័យពិធីការ និងការិយាល័យលេខាធិការ។

នៅ**អណត្តិទី២** **ឯកឧត្តម កុល ផេង** អគ្គលេខាធិការរដ្ឋសភាពេលនោះ បានកែសំរួល រចនាសម្ព័ន្ធបង្កើតនាយកដ្ឋាន៧រួមមាន៖

១-នាយកដ្ឋានរដ្ឋបាល ប្រធាន គឺ**លោក ម៉ូច តុង ហ៊ាត**
មកពីគណបក្សហ៊្វុនស៊ិនប៉ិច

២-នាយកដ្ឋានបុគ្គលិក ប្រធាន គឺ**លោក ឡាច លាង**
មកពីគណបក្សប្រជាជនកម្ពុជា

៣-នាយកដ្ឋានហិរញ្ញវត្ថុ ប្រធាន គឺ**លោក មិត្ត ភារ៉េន**
មកពីគណបក្សប្រជាជនកម្ពុជា

៤-នាយកដ្ឋានទំនាក់ទំនងអន្តរជាតិប្រធាន គឺ**លោក កែម សុផុនណា**
មកពីគណបក្សហ៊្វុនស៊ិនប៉ិច

៥-នាយកដ្ឋាននីតិវិធី ប្រធាន គឺ**អ្នកស្រី ស៊ឹង ស៊ីយុត**
មកពីគណបក្សប្រជាជនកម្ពុជា

៦-នាយកដ្ឋានស្រាវជ្រាវច្បាប់ ប្រធាន គឺ**លោក មុយ ប៊ុន**
មកពីគណបក្សហ៊្វុនស៊ិនប៉ិច

៧-នាយកដ្ឋានព័ត៌មាន ប្រធាន គឺ**លោក គឹម វិមល**
មកពីគណបក្សហ៊្វុនស៊ិនប៉ិច

និងមាន២ការិយាល័យគឺ ការិយាល័យលេខាធិការ និងការិយាល័យសន្តិសុខ។

នៅ**អណត្តិទី៣** ២០០៣ ក្នុងដើមអណត្តិ **ឯកឧត្តម កុល ផេង** អគ្គលេខាធិការរដ្ឋសភា បានកែសំរួលរចនាសម្ព័ន្ធថ្មីលេខ០១៨ បង្កើតអគ្គនាយកដ្ឋាន២ ចំណុះដោយនាយកដ្ឋាន១០មាន៖

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានតែងតាំងលោក **ឈឹម ថេត** ជាអគ្គនាយក និង អគ្គនាយកដ្ឋាន សេវា និងបច្ចេកទេស តែងតាំងលោក **មិត្ត ភារ៉េន** ជាអគ្គនាយក តែការតែងតាំង នេះត្រូវបានគណបក្សប្រជាជនជំទាស់យ៉ាងខ្លាំង និងស្នើធ្វើការកែសំរួលវិញ។ នៅអណត្តិទី៣នេះ **ឯកឧត្តម គឹម សាន្ត** ឡើងមកធ្វើអគ្គលេខាធិការរដ្ឋសភា។

ដោយបានឯកភាពគ្នាពីថ្នាក់ដឹកនាំរដ្ឋសភា រចនាសម្ព័ន្ធត្រូវបានយកមកកែសម្រួលវិញ ដោយបានបង្កើតគណៈកម្មការរៀបចំមួយ ចូលរួមដោយតំណាងគណបក្សប្រជាជនកម្ពុជា៣នាក់ និងគណបក្សហ៊ុនសុិនប៉ិច ៣នាក់ ហើយបានឯកភាពគ្នាថា ការរៀបចំត្រូវចែកគ្នាម្ខាងៗ ៥០ ភាគរយ តែគណៈកម្មការនេះត្រូវបានលុបចោលវិញ ដោយសារសម្តេចក្រុមព្រះ ប្រធានរដ្ឋសភាបានលាលែងពីប្រធានរដ្ឋសភា នៅខែកុម្ភៈ ឆ្នាំ២០០៦។

នៅខែមេសា ឆ្នាំ២០០៦ គណបក្សប្រជាជនកម្ពុជា ដឹកនាំរដ្ឋសភាខ្លួនឯង បានរៀបចំរចនាសម្ព័ន្ធថ្មី១ទៀត លេខ០៣៥ និងតែងតាំងមន្ត្រីដោយគ្មានកិច្ចព្រមព្រៀង និងគោលការណ៍ឯកភាពដូចមុនទៀតឡើយ ហើយបានតែងតាំងដោយ**សម្តេច ហេង សំរិន** ប្រធានរដ្ឋសភាៈ

**១-<u>អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ</u>**

លោក **មិត្ត ភារ៉េន** ប្រធាន

-នាយកដ្ឋានបុគ្គលិក លោក **អៀ ចាន់រ៉ាឌី** ប្រធាន មកពីគណបក្សប្រជាជនកម្ពុជា

-នាយកដ្ឋានរដ្ឋបាល លោក **អុិច សំអុល** ប្រធាន មកពីគណបក្សប្រជាជនកម្ពុជា

-នាយកដ្ឋានសារពើភ័ណ្ឌ លោក **ញ៉ែម សាវើយ** ប្រធាន មកពីគណបក្សប្រជាជនកម្ពុជា

-នាយកដ្ឋានហិរញ្ញវត្ថុ លោក **ហេង្យ វិចិត្រ** ប្រធាន មកពីគណបក្សប្រជាជនកម្ពុជា

-នាយកដ្ឋានពិធីការ លោក **ព្រហ្ម វីរៈ** ប្រធាន មកពីគណបក្សប្រជាជនកម្ពុជា

**២-<u>អគ្គនាយកដ្ឋាន សេវា និង បច្ចេកទេស</u>**

អ្នកស្រី **ស៊ីង ស៊ីយុត**ប្រធាន

-នាយកដ្ឋាននីតិវិធី លោក **ហួត ពៅ** ប្រធាន មកពីគណបក្សប្រជាជនកម្ពុជា

-នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

លោក **អុ៊ុយ វិសាល** ប្រធាន មកពីគណបក្សប្រជាជនកម្ពុជា

-នាយកដ្ឋានព័ត៌មាន លោក **កែម សុផុនណា** ប្រធាន មកពីគណបក្សហ៊្វុនសុិនប៉ិច

-នាយកដ្ឋានសភាខេត្ត-ក្រុង លោក **ឈុន ច័ន្ទបូរ៉ា** ប្រធាន មកពីគណបក្សហ៊្វុនសិុនប៉ិច

-នាយកដ្ឋានស្រាវជ្រាវច្បាប់ **ព្រះអង្គម្ចាស់ នរោត្តម ដារ៉ារ៉េត**

ប្រធាន មកពីគណបក្សហ៊្វុនសិុនប៉ិច

-នៅឆ្នាំ២០១១ បានបង្កើតនាយកដ្ឋានសវនកម្ម

លោក **មិត្ត ទីមាន** ប្រធាន មកពីគណបក្សប្រជាជនកម្ពុជា

ដូចនេះ ការតែងតាំងមន្ត្រីក៏មិនបានធ្វើតាមគោលការណ៍បង្រួបបង្រួមជាតិ ឬតែងតាំងដោយសម្តេចក្រុមព្រះឡើយ គឺដោយគណបក្សប្រជាជនកម្ពុជាខ្លួនឯង ហើយមិនត្រូវទំលាក់កំហុសទៅលើសម្តេចក្រុមព្រះទេ។